CITY OF
LONG BEACH

August 2025

# ព័ត៌មានថ្មីជុំវិញឧប្បត្តិហេតុសន្តិសុខទិន្នន័យ–សំណួរដែលគេសួរញឹកញាប់

**បានធ្វើបច្ចុប្បន្នភាព ខែសីហា ឆ្នាំ ២០២៥:** ព័ត៌មានខាងក្រោមដែលបានផ្តល់ដំណឹងដំបូងនៅថ្ងៃទី ១៤ ខែមេសា ឆ្នាំ ២០២៥ អាចនឹងហួសសម័យ និង/ឬមិនអាចអនុវត្តបានទៀតទេ ដោយសារទីក្រុងឡុងប៊ិចបានបញ្ចប់រយៈពេលជូនដំណឹង ដែលត្រូវការចំនួន ៩០ ថ្ងៃ។ មជ្ឈមណ្ឌលហៅទូរស័ព្ទដែលត្រូវបានបង្កើតឡើងដើម្បីផ្តល់ព័ត៌មានបន្ថែម និងធនធានដល់អ្នកដែលរងផលប៉ះពាល់ បានដំណើរការចាប់ពីថ្ងៃទី ១៤ ខែមេសា ដល់ថ្ងៃទី ១៤ ខែកក្កដា ហើយឥឡូវនេះត្រូវបានបិទ។ ទីក្រុងបានអនុវត្តតាមច្បាប់ដែលចូលជាធរមានទាំងអស់ ដែលទាក់ទងនឹងការជូនដំណឹងសម្រាប់ការធ្វើបច្ចុប្បន្នភាពនេះ។ ពេលនេះ មិនទំនងថានិងមានការធ្វើបច្ចុប្បន្នភាពបន្ថែមទៀតទេ ទាក់ទងនឹងឧប្បត្តិហេតុសុវត្ថិភាពបណ្តាញ ដែលបានកើតឡើងនៅថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០២៣ ឬប្រហាក់ប្រហែលថ្ងៃនោះ។

## វិធីសាស្ត្ររាប់ CLB សម្រាប់ការប្រមូលទិន្នន័យ

សាលាក្រុងឲ្យតម្លៃ និងគោរពចំពោះព័ត៌មានផ្ទាល់ខ្លួន ដែលសាលក្រុងរក្សាទុក។ សាលាក្រុងបានប្តេជ្ញារក្សាភាពស្មោះសឥតលាក់លៀម និងមានតម្លាជាមួយសហគមន៍។ ការស៊ើបអង្កេត រកមើលឧប្បត្តិហេតុសន្តិសុខទិន្នន័យ ដែលកើតឡើងនៅចំ ឬនៅម៉ឺថ្ងៃទី ១៤ ខែ វិច្ឆកា ឆ្នាំ ២០២៣ បានបង្ហាញឲ្យឃើញថា សំណុំឯកសារដែលមានរក្សាទុកព័ត៌មានផ្ទាល់ខ្លួនមួយចំនួន ត្រូវបានគេចូលបើកមើលបាន និង/ឬលួចយកទៅរក្សាទុក។ ឥឡូវនេះ សាលាក្រុងកំពុងបំពេញបែបបទ ដើម្បីជូនដំណឹងប្រជាពលរដ្ឋ ដែលព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគាត់ អាចត្រូវបានគេចូលបើកមើលបាន និង/ឬលួចយកទៅរក្សាទុក។ សាលាក្រុងកំពុងផ្ញើសំបុត្រជូនបងប្អូនដែលរងផលប៉ះពាល់ទាំងនោះ តាមប្រៃសនីយ៍អាមេរិក។ ក្នុងពេលនេះ យើងមិនឃើញមានសញ្ញាណថាព័ត៌មានណាមួយ ត្រូវបានប្រើប្រាស់ក្នុងបំណងមិនត្រឹមត្រូវ ដូចជាយកទៅប្រព្រឹត្តអំពើឆបោក ឬលួចប្រើអត្តសញ្ញាណនោះឡើយ។ សាលាក្រុងផ្តល់ព័ត៌មាននេះជូនបងប្អូន ក្នុងន័យយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នខ្ពស់ និងអនុលោមតាមច្បាប់ ដើម្បីឲ្យបងប្អូនដែលរងផលប៉ះពាល់ មានព័ត៌មាននៅក្នុងដៃ មានឧបករណ៍ និងធនធាន សម្រាប់ការពារព័ត៌មានផ្ទាល់ខ្លួនរបស់បងប្អូន។

## តើព័ត៌មានអ្វីខ្លះដែលពាក់ព័ន្ធ?

សំណុំឯកសារដែលអាចប៉ះពាល់ គឺនាម និងត្រកូល ដោយទាំងព័ត៌មានមួយ ឬច្រើនដូចតទៅនេះផង៖ ថ្ងៃខែឆ្នាំកំណើត ព័ត៌មានអំពីគណនីហិរញ្ញវត្ថុ ព័ត៌មានអំពីកាតក្រេឌីត និង/ឬ កាតដេប៊ិត, លេខសូស្យាល់ ព័ត៌មាននៃការផ្តិតម្រាមដៃ ព័ត៌មានអំពីរោគសញ្ញាដែលរកឃើញ និង/ឬការព្យាបាល ព័ត៌មានអំពីគ្រូពេទ្យ ព័ត៌មានអំពីធានារ៉ាប់រងសុខភាព លេខប័ណ្ណបើកបរ លេខលិខិតឆ្លងដែន លេខកំណត់ហេតុសុខភាព លេខសម្គាល់អ្នកបង់ពន្ធ និងព័ត៌មានអំពីគណនីអ្នកជំងឺ។ ប្រភេទនេះព័ត៌មានផ្ទាល់ខ្លួន ដែលពាក់ព័ន្ធ មានភាពខុសៗគ្នាទៅតាមមនុស្សម្នាក់ៗ ហើយមិនមែនម្នាក់ៗសុទ្ធតែរងផលប៉ះពាល់គ្រប់ធាតុនៃទិន្នន័យនោះដែរ។

## តើសាលាក្រុងធ្វើយ៉ាងដូចម្តេចចំពោះរឿងនេះ?

សាលាក្រុងកំពុងរៀបចំបែបបទ ដើម្បីផ្ញើលិខិតជូនដំណឹងតាមប្រៃសនីយ៍អាមេរិក ទៅជូនបងប្អូនដែលរងផលប៉ះពាល់ ដោយយើងផ្ញើលិខិតនោះទៅតាមអាសយដ្ឋានចុងក្រោយ ដែលសាលាក្រុងមានក្នុងបញ្ជី។ លិខិតនោះពន្យល់អំពីសេវាអ្វីខ្លះ ដែលមានសម្រាប់ជួយអ្នករងផលប៉ះពាល់នោះ និងមានផ្តល់ជាវិធានដើម្បីជួយការពារទប់ទល់នឹងការលួចបន្លំអត្តសញ្ញាណ។ ជាមួយគ្នានេះ សាលាក្រុងក៏បង្ហាញជូនព័ត៌មានដូចគ្នានេះ នៅលើគេហទំព័រ longbeach.gov ដើម្បីធ្វើយ៉ាងណា ឲ្យបងប្អូនសាធារណជនទូទៅ ដែលជឿថាពួកគាត់គួរទទួលបានលិខិតនោះ ប៉ុន្តែបែរជាមិនបាន។ មិនតែប៉ុណ្ណោះ សាលាក្រុងក៏បានបង្កើតមជ្ឈមណ្ឌលទូរស័ព្ទមួយ ដែលមានបុគ្គលិកជំនាញ ដែលយល់ដឹងអំពីឧប្បត្តិហេតុនេះ ដើម្បីផ្តល់ព័ត៌មាន និងធនធាន។ បងប្អូនអាចទូរស័ព្ទទៅមជ្ឈមណ្ឌលនេះតាមលេខ 888.802.9667 ពីថ្ងៃ ចន្ទ ដល់ សុក្រ ពីម៉ោង ៦ព្រឹក ដល់ ៦ល្ងាច ម៉ោង Pacific Time លើកលែងតែថ្ងៃឈប់សម្រាកបុណ្យជាតិ។ ទន្ទឹមនឹងនេះ សាលាក្រុង ក៏ផ្តល់ជូនសេវាតាមដានក្រេឌីត សម្រាប់អ្នកដែលរងផលប៉ះពាល់ដោយសារគេលួចលេខសូស្យាល់។

## តើប្រព័ន្ធរបស់សាលាក្រុងមានសុវត្ថិភាពក្នុងការប្រើប្រាស់ដែរឬទេ?

បាទ/ចាស ប្រព័ន្ធរបស់សាលាក្រុងឡុងប៊ិច នៅតែមានសុវត្ថិភាពសម្រាប់ប្រើប្រាស់។ កាលពីពេលដែលសាលាក្រុង ដឹងពីដំបូងអំពីឧប្បត្តិហេតុសន្តិសុខ ដែលកើតឡើងនៅថ្ងៃ ឬប្រហែលថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២៣នោះ សាលាក្រុងយកចិត្តទុកដាក់ខ្ពស់ និងប្រុងប្រយ័ត្នបំផុត ដោយផ្អាកប្រើប្រព័ន្ធអនឡាញរបស់យើងជាបណ្តោះអាសន្ន ក្នុងពេលបើកការស៊ើបអង្កេត និងរកដំណោះស្រាយ។ អំឡុងពេលនោះ សេវាសំខាន់ៗស្ទើរតែទាំងអស់របស់សាលាក្រុង មិនរងផលប៉ះពាល់នោះទេ និងនៅបន្តបើកដំណើរការដូចធម្មតា។ រាល់ប្រព័ន្ធដែលរងផលប៉ះពាល់ទាំងអស់ ត្រូវបានស្តារឡើងវិញ ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ក្រោយមក។

## ហេតុអ្វីសាលាក្រុងត្រូវការពេលយូរម្ល៉េះ ទម្រាំអាចប្រាប់ដំណឹងទៅអ្នកដែលរងផលប៉ះពាល់?

ការស៊ើបអង្កេតឧប្បត្តិហេតុសន្តិសុខប្រព័ន្ធរបស់យើងនេះ បានប្រព្រឹត្តទៅតាំងពីខែ វិច្ឆិកា ឆ្នាំ ២០២៣ និងមានស៊ើបអង្កេតបែបកោសលវិច្ច័យ យ៉ាងស៊ីជម្រៅ និងការត្រួតពិនិត្យឯកសារដោយផ្ទាល់ដៃ ដែលត្រូវការប្រើពេលប្រមាណ ១៥ខែ ទើបចប់សព្វគ្រប់។ អ្នកដែលធ្លាប់ជួបប្រទះឧប្បត្តិហេតុដ៏ស្មុគស្មាញ គង់ដឹងថាដំណើរការនេះ គឺជាដំណើរការមួយដែលត្រូវចំណាយពេលយូរ។ យើងយកចិត្តទុកដាក់ចាត់ការសន្តិសុខព័ត៌មានយ៉ាងម៉ឺងម៉ាត់ និងត្រូវធ្វើយ៉ាងណា ទាល់តែយើងច្បាស់ប្រាកដលើលទ្ធផលនៃការស៊ើបអង្កេត ទើបយើងចេញសេចក្តីជូនដំណឹង។ ផ្អែកលើការចង្អុលបង្ហាញ ពីក្រុមប្រឹក្សាច្បាប់ និងអ្នកជំនាញផ្នែកទិន្នន័យឯកជនខាងក្រៅ និងឲ្យស្របតាមការអនុវត្តល្អៗ ក្នុងរឿងសន្តិសុខតាមអនឡាញនេះ សាលាក្រុងបានបិទបញ្ចប់ការស៊ើបអង្កេត និងបានកំណត់ថា ព័ត៌មានផ្ទាល់ខ្លួនរបស់ឈ្មោះបុគ្គលជាច្រើន ត្រូវបានរងផលប៉ះពាល់ និងប្រភេទទិន្នន័យ ដែលមានគេលួចចូលបើកមើលបាន និង/ឬលួចយកទៅរក្សាទុក។

## ហេតុអ្វីខ្ញុំទទួលបានការជូនដំណឹងពីសាលាក្រុង?
អ្នកទទួលបានសេចក្តីជូនដំណឹង ដោយសារការស៊ើបអង្កេត បានរកឃើញថា ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ត្រូវបានគេលួចចូលមើលបាន និង/ឬលួចរក្សាទុក។ ការថែរក្សាការពារឯកជនភាព និងសន្តិសុខព័ត៌មានរបស់អ្នក គឺចំណុចអាទិភាពរបស់សាក្រុងឡុងបិច។ សាលាក្រុងគោរព និងឲ្យតម្លៃលើភាពជាឯកជនរបស់បងប្អូន។ ដោយសារតែមូលហេតុនេះហើយ ទើបយើងជូនជំណឹងបងប្អូន អំពីឧប្បត្តិហេតុ ដើ្បធ្វើយ៉ាងឲ្យបងប្អនយល់ដឹង និងមានព័ត៌មាន និងធនធាន ដើម្បីការពារ បើអ្នកត្រូវការវា។

## ខ្ញុំទទួលបានសេចក្តីជូនដំណឹងពីសាលាក្រុង អំពីឧប្បត្តិហេតុសន្តិសុខ។ តើនេះមានន័យថាមាននរណាម្នាក់ បានលួចយកព័ត៌មានរបស់ខ្ញុំទៅប្រើប្រាស់ផ្តេសផ្តាស?
សាលាក្រុងពុំទទួលរបាយការណ៍អំពីការបោកបន្លំណាមួយ ដែលកើតចេញពីឧប្បត្តិហេតុនេះទេ។ សាលាក្រុងបានផ្តល់ជូនសេចក្តីជូនដំណឹង តាមរយៈសំបុត្រ ដើម្បីឲ្យបងប្អូនបានដឹងអំពីរឿងនេះ និងផ្តល់ជូនជាការណែនាំ ដើម្បីបងប្អូនអាចបន្តការពារខ្លួន។

## តើសាលាក្រុងផ្តល់សេវាតាមជួយតាមដានមើលក្រេឌីតឬទេ?
សាលាក្រុងផ្តល់ការតាមដានមើលក្រេឌីតនេះ សម្រាប់អ្នកទាំងអស់ដែលលេខសូស្យាល់របស់ពួកគាត់ អាចរងផលប៉ះពាល់។

## តើខ្ញុំអាចធ្វើអ្វីបានខ្លះដើម្បីការពារខ្លួន?
សាលាក្រុងលើកទឹកចិត្ត ឲ្យបងប្អូនចាត់វិធានការបង្ការដូចខាងក្រោម៖
- សូមពិនិត្យលិខិតដែលបងប្អូនបានទទួលនោះ ដោយយកចិត្តទុកដាក់ ដើម្បីយល់ដឹងអំពីប្រការដែលត្រូវអនុវត្ត ក្នុងការការពារខ្លួន។ សេចក្តីជូនដំណឹងនោះមានព័ត៌មានអំពីឧប្បត្តិហេតុនោះ មានការឆ្លើយតបរបស់យើងខ្ញុំ និងព័ត៌មាននិងធនធានផ្សេងៗ ដើម្បីជួយការពារព័ត៌មានរបស់បងប្អូន។
- សូមចុះឈ្មោះទទួលសេវាតាមមើលក្រេឌីត ដែលយើងផ្តល់ជូនដោយឥតគិតថ្លៃ បើបងប្អូនបំពេញគ្រប់លក្ខខណ្ឌ។
- បងប្អូនគួរតែប្រុងប្រយ័ត្នខ្ពស់ជាប់ជានិច្ច ចំពោះឧប្បត្តិហេតុនៃការលួចយកអត្តសញ្ញាណបងប្អូនទៅប្រើប្រាស់ ដោយបងប្អូនត្រូវតាមដានរបាយការណ៍គណនីហិរញ្ញវត្ថុរបស់បងប្អូន និងតាមដានរបាយការណ៍ក្រេឌីត ដោយឥតគិតថ្លៃនោះ ដើម្បីរកមើលបញ្ហា ឬកំណត់សកម្មភាពដែលគួរឲ្យសង្ស័យណាមួយ។
- បងប្អូនអាចកំណត់សារជូនដំណឹងអំពីការបោកបន្លំ និង/ឬបង្កាក់សកម្មភាពគួរឲ្យ សង្ស័យ នៅក្នុងប្រព័ន្ធក្រេឌីតរបស់បងប្អូន។
- បងប្អូនអាចស្នើសុំរបាយការណ៍ក្រេឌីត ដោយឥតគិតថ្លៃបាន។

## តើខ្ញុំដាក់ពាក្យប្តឹងទៅប៉ូលិសនៅឯណា?
បើបងប្អូនរកឃើញថា មានហេតុផល ដែលបងប្អូនជឿថា ព័ត៌មានផ្ទាល់ខ្លួនរបស់បងប្អូន ត្រូវបានគេលួចយកទៅប្រព្រឹត្តអំពើឆបោក ឬបទឧក្រិដ្ឋផ្សេងទៀតមកលើបងប្អូន សូមដាក់ពាក្យប្តឹងទៅប៉ូលិស នៅក្នុងទីក្រុងដែលបងប្អូនកំពុងរស់នៅ។ កុំភ្លេចសុំឯកសារចម្លងរបាយការណ៍ប៉ូលិសមួយច្បាប់ផង ដ្បិតស្ថាប័នផ្តល់ក្រេឌីតជាច្រើន ចង់បានព័ត៌មាននៅក្នុងរបាយការណ៍នោះ ដើម្បីលុបឈ្មោះបងប្អូន ចេញពីបញ្ជីខ្មៅនៃបំណុលពីអំពើឆបោកនោះ។
- អ្នករស់នៅទីក្រុងឡុងប៊ិច អាចសុំរបាយការណ៍ប៉ូលិសនេះបាន ដោយទូរស័ព្ទទៅនាយកដ្ឋានប៉ូលិសក្រុងឡុងប៊ិច តាមខ្សែទូរស័ព្ទដែលមិនបន្ទាន់៖ 562.435.6711។
- បងប្អូនក៏អាចដាក់ពាក្យប្តឹងជាមួយគណៈកម្មការពាណិជ្ជកម្មជាតិ (FTC) អនឡាញ ដោយទូរស័ព្ទទៅលេខ៖ 1.877.IDTHEFT (1.877.438.4338), ឬផ្ញើសំបុត្រទៅ Federal Trade Commission, Consumer Response Center, 600 Pennsylvania Avenue, NW, Washington, DC 20580។

## តើហេតុការណ៍នេះ ធ្វើឲ្យអ្នកបង់ពន្ធនៅទីក្រុងឡុងប៊ិច ខាតបង់ប៉ុន្មាន?
ភាគច្រើននៃការខូចខាត ដែលកើតឡើងពីឧប្បត្តិហេតុនេះ គឺជាថ្លៃចំណាយប្រតិបត្តិការពីកញ្ចប់ថវិកាទូទៅ (មូលនិធិសេវាផ្ទៃក្នុង) របស់នាយកដ្ឋានបច្ចេកវិទ្យា និងនិវានុវត្តន៍។

## តើសាលាក្រុងត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីធានាថាបញ្ហានេះលែងកើតមានទៀត?
យើងយកចិត្តទុកដាក់បំផុត លើបញ្ហាឯកជនភាព និងសន្តិសុខនៃព័ត៌មាន ដែលប្រជាពលរដ្ឋទុកចិត្តយើងខ្ញុំ។ ទោះបីជាមានវិធានការពាររួចទៅហើយក្តី ក៏យើងខ្ញុំបន្តពិនិត្យមើល និងពង្រឹងកិច្ចការពារនេះបន្ថែមទៀតដែរ។ យើងខ្ញុំចាត់វិធានការចាំបាច់នានា ដើម្បីការពារឲ្យបានប្រសើរបំផុត កុំឲ្យឧប្បត្តិហេតុស្រដៀងនេះ កើតមានម្តងទៀតទៅថ្ងៃអនាគត។

ជារៀងរាល់ឆ្នាំ ទីក្រុងឡុងប៊ិចបន្តវិនិយោគក្នុងការពង្រឹងវិធានការសន្តិសុខតាមប្រព័ន្ធអនឡាញនេះ។ នៅក្នុងថវិកាដែលបានឯកភាពរួច សម្រាប់ឆ្នាំសារពើពន្ធ ២០២៥ មានទឹកប្រាក់ ១ លានដុល្លារ ត្រូវបានសម្រាំងសម្រាប់ប្រើប្រាស់ក្នុងផ្នែកពង្រឹងសន្តិសុខប្រព័ន្ធអនឡាញ និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យារបស់យើង តាមរយៈការប្រើប្រាស់អ្នកជំនាញផ្នែកសន្តិសុខអនឡាញ ការបណ្តុះបណ្តាល ការធ្វើតេស្ត វិធានបង្ការការបាត់បង់ទិន្នន័យ និងច្រើនទៀត។ សាលាក្រុងឡុងប៊ិចនៅបន្តវាយតម្លៃ និងកែសម្រួលការអនុវត្តរបស់ខ្លួន ដើម្បីពង្រឹងសន្តិសុខ និងឯកជនភាពនៃព័ត៌មានផ្ទាល់ខ្លួនរបស់ប្រជាពលរដ្ឋ ដែលមានរក្សាទុកក្នុងប្រព័ន្ធទិន្នន័យរបស់សាលាក្រុង និងតម្រូវឲ្យបុគ្គលិកសាលាក្រុងទាំងអស់ បំពេញវគ្គបណ្តុះបណ្តាលអំពីការយល់ដឹងអំពីសន្តិសុខតាមអនឡាញនេះជាកំហិត ដែលនេះជាបច្ចេកទេសការពារមួយក្នុងចំណោមកិច្ចការពារជាច្រើនទៀត។

## តើអ្នកលួចយកព័ត៌មានរបស់យើង (តួអង្គគ្រោះថ្នាក់) លួចចូលប្រព័ន្ធអនឡាញរបស់សាលាក្រុងបានយ៉ាងដូចម្ដេច? ហេតុអ្វីសាលាក្រុងមិនបានចាត់វិធានការបង្ការទុកជាមុន ដើម្បីទប់កុំឲ្យរឿងនេះកើតឡើង?

យើងខ្ញុំមិនអាចបង្ហាញអំពីព័ត៌មានលម្អិតជាក់លាក់ ដោយសារតែបញ្ហាគិតគូររឿងសន្តិសុខ ដ្បិតការចែករំលែកព័ត៌មាននេះ អាចធ្វើឲ្យផុយស្រួយដល់ប្រព័ន្ធរបស់យើង ដែលនឹងធ្វើឲ្យជនប្រព្រឹត្ត ងាយចូលបំពានបន្តទៀត។ សាលាក្រុងបានវិនិយោគ ហើយនឹងបន្តវិនិយោគលើវិធានការសន្តិសុខប្រព័ន្ធអនឡាញនេះ។ មិនតែប៉ុណ្ណោះ យើងខ្ញុំចង់បញ្ជាក់ធានាជូនបងប្អូនសាធារណជនថា សាលាក្រុងបានចាត់វិធានការជាបន្ទាន់ ដើម្បីគ្រប់គ្រងឧប្បត្តិហេតុនោះ និងបានពង្រឹងកិច្ចការពាររបស់យើងបន្ថែម ហើយបានសហការគ្នាជាមួយអ្នកជំនាញផ្នែកសន្តិសុខប្រព័ន្ធអនឡាញ ដើម្បីបង្ការកុំឲ្យរឿងនេះកើតមានទៀត។ កិច្ចការពារប្រព័ន្ធ និងព័ត៌មានរបស់យើង ដែលបងប្អូនទុកចិត្តយើងខ្ញុំឲ្យថែរក្សានេះ គឺនៅតែជាចំណុចអាទិភាពខ្ពស់បំផុតមួយនៃការងាររបស់យើង។

## តើដល់អង្កាល់ទើបខ្ញុំអាចដឹងបន្ថែមអំពីឧប្បត្តិហេតុផ្នែកសន្តិសុខប្រព័ន្ធអនឡាញនេះ?

ព័ត៌មានបន្ថែមអំពីឧប្បត្តិហេតុផ្នែកសន្តិសុខប្រព័ន្ធអនឡាញនេះ មាននៅ៖ longbeach.gov/networksecurityincident។ ព័ត៌មានថ្មីៗបន្ថែមអំពីការស៊ើបអង្កេតក្នុងរឿងនេះ គឺមាននៅគេហទំព័ររបស់សាលាក្រុងឡុងប៊ិច longbeach.gov។

## តើអង្កាល់ទើបមានព័ត៌មានថ្មីទៀតអំពីរឿងនេះ?

ដោយសារតែការស៊ើបអង្កេតរឿងសន្តិសុខប្រព័ន្ធអនឡាញនេះ ត្រូវបានបិទបញ្ចប់ទៅហើយ នេះចាត់ទុកថាជាព័ត៌មានថ្មីនិងចុងក្រោយសម្រាប់បញ្ហានេះ។

## ខ្ញុំមានសំណួរបន្ថែម តើខ្ញុំគួរធ្វើយ៉ាងដូចម្ដេច?

បងប្អូនដែលមានសំណួរបន្ថែម គួរទូរស័ព្ទទៅកាន់មជ្ឈមណ្ឌលសម្រាប់ឆ្លើយតបពលរដ្ឋ តាមលេខ៖ 888.802.9667។ មជ្ឈមណ្ឌលទូរស័ព្ទនេះ មានបុគ្គលិកជំនាញអាជីព ដែលយល់ដឹងអំពីករណីនេះ និងអាចផ្ដល់ព័ត៌មាន និងធនធានផ្សេងៗជូនបងប្អូនបាន។ មជ្ឈមណ្ឌលទូរស័ព្ទនេះ បើកទ្វារពីថ្ងៃ ចន្ទ ដល់ថ្ងៃ សុក្រ ចាប់ពីម៉ោង ៦ព្រឹក ដល់ ៦ល្ងាច ម៉ោង Pacific Time លើកលែងតែឈប់សម្រាក។

## ខ្ញុំអត់ចេះនិយាយភាសាអង់គ្លេស។ តើមានសេវាបកប្រែភាសាណាសម្រាប់រូបខ្ញុំដែរឬទេ?

- បងប្អូនដែលត្រូវការសេវាបកប្រែភាសាផ្ទាល់មាត់ គួរទូរស័ព្ទទៅកាន់មជ្ឈមណ្ឌលទូរស័ព្ទនោះតាមលេខ៖ 888.802.9667។ អ្នកទៅទីនោះនឹងភ្ជាប់ទៅខាងសេវាបកប្រែភាសាផ្ទាល់មាត់។